ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១២ លេខ ១ | មករា - មីនា ឆ្នាំ២០០៨ | តម្លៃ ១.៥០០៛

# របាយការណ៍សង្ខេបអំពីស្ថាប័នគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា

**លោក ច័ន្ទ សុផល ពិនិត្យពីបទប្បញ្ញត្តិ និងស្ថាប័នគ្រប់គ្រងចំណាកស្រុកពលករចេញពីកម្ពុជា និងគូសបញ្ជាក់ពីបញ្ហាសេដ្ឋកិច្ច-នយោបាយធំៗ ដែលរារាំងការកសាងប្រព័ន្ធល្អមួយសំរាប់គ្រប់គ្រងចំណាកស្រុកពលករ ព្រមទាំងលើកឡើងនូវ ដំណោះស្រាយមួយចំនួន ។***

ពាក់ព័ន្ធនឹងស្ថាប័ន គោលនយោបាយ និង ក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា ប្រទេសកម្ពុជា នៅមានបទពិសោធន៏តិចជាងប្រទេសដទៃទៀត ។ ពលករភាគច្រើន ធ្វើដំណើរតាមមធ្យោបាយមិនផ្លូវការ រឺខុសច្បាប់ រីឯមធ្យោបាយស្របច្បាប់វិញ ទើបនឹងមានអនុវត្តក្នុងពេលថ្មីៗ ហើយត្រូវចំណាយអស់ច្រើន និងស្មុគស្មាញ ។ ស្ថាប័នរដ្ឋនានា នឹងត្រូវប្រឈមបញ្ហាកាន់តែច្រើន ចំពោះការគ្រប់គ្រងចំណាកស្រុកចេញរបស់ពលករដែលរំពឹងថានឹងកើនឡើង ដោយសារកត្តាទាំងខាងក្នុង និងខាងក្រៅ ។ ការធ្វើចំណាកស្រុក ទំនងជានឹងកើនឡើង ដោយសារការបង្កើតការងារក្នុងស្រុក មានល្បឿនយឺតជាង កំណើនពលករប្រចាំឆ្នាំ ដែលមានប្រហែល ៣០០.០០០នាក់ ។ ប្រាក់បៀវត្សរ៏ខ្ពស់ជាង និងតំរូវការពលករនៅប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង សិង្ហបុរី និងជប៉ុន គឺជាកត្តាទាក់ទាញពីខាងក្រៅ ។


*កម្មករចំណាកស្រុកកម្ពុជា ជួសជុលសំណាញ់មុនពេលចុះនេសាទ ។ ក្នុងមួយឆ្នាំៗ កម្មករប្រមាណ 180.000 នាក់ ចូលទៅក្នុងទឹកដីថៃខុសច្បាប់ ។*

ទោះជាយើងពេញចិត្តនឹងការបង្កើតឱកាសការងារ និងអភិវឌ្ឍន៏នៅក្នុងប្រទេសជាងក្តី ក៏យើងគួរមាន ប្រព័ន្ធគ្រប់គ្រង គោលនយោបាយ នឹងក្របខ័ណ្ឌច្បាប់ដ៏ល្អ សំរាប់គ្រប់គ្រងចំណាកស្រុកពលករដែរ ពីព្រោះចំណាកស្រុកអាចផ្តល់ ឱកាសការងារ និងចំណូលចាំបាច់សំរាប់រយ:ពេលខ្លី និងមធ្យម ។ មិនតែប៉ុណ្ណោះ វាក៏អាចជួយកាត់បន្ថយភាពក្រីក្រផងដែរ ។ ប្រាក់ផ្ញើមកផ្ទះ មានតួលេខប៉ាន់ស្មានប្រហែល ២០០លានដុល្លារ រឺ ៣,២៣% នៃផសស ឆ្នាំ២០០៥ ហើយយើងរំពឹងថា អាចកើនឡើងរហូតដល់ ៥០០លានដុល្លារ បើសិនមានការគ្រប់គ្រងចំណាកស្រុកពលករបានប្រសើរជាងមុន ។

នៅឆ្នាំ២០០៥ ប្រទេសថៃបានបញ្ជូនពលករចំណាកស្រុកចេញ ១៦០.០០០នាក់ និងទទួលបានប្រាក់ផ្ញើមកផ្ទះ ១,២ពាន់លានដុល្លារ រីឯវៀតណាមបានបញ្ជូលពលករ ប្រហែល ៤០០.០០០នាក់ និងទទួលបានប្រាក់ផ្ញើមកផ្ទះ ប្រមាណ ៤ពាន់លានដុល្លារ យោងតាមសូចនាករអភិវឌ្ឍន៏

* ច័ន្ទ សុផល ជាអ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ ។ អត្ថបទនេះជាសង្ខេបនៃសេចក្តីព្រាងរបាយការណ៏ដែលវិទ្យាស្ថាន CDRI កំពុងសរសេរ ដោយមានការឧបត្ថម្ភថវិកា ដោយអង្គការពលកម្មអន្តរជាតិ (ILO) និងសហការជិតស្និតជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ: ។ យោបល់ ឬកំហុសដោយអចេតនា គឺជារបស់អ្នកនិពន្ធ និងមិនមែនជារបស់ CDRI ឬអង្គការ ILO ទេ ។

## មាតិកា

របាយការណ៍សង្ខេបអំពីស្ថាប័នគោលនយោបាយ ........ ១
ការគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា ........ ៦
ការវិញលក់ដីធ្លី និងបញ្ហា ផុសឡើងក្រោយពេលចាប់ផ្តើមចុះបញ្ជីដីធ្លី ........ ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៥
— ស្ថានភាពក្នុងប្រទេស ........ ១៨
— សន្ទស្សន៍សេដ្ឋកិច្ច ........ ២១
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........ ២៤

ពិភពលោក (World.Development.Indicators) ឆ្នាំ២០០៧ ផ្សព្វផ្សាយដោយធនាគារពិភពលោក។ ប្រទេសហ្វីលីពីន បានទទួលប្រាក់ផ្ញើមកផ្ទះ ១៣,៩ពាន់លានដុល្លារ (១៣,៧%នៃ ផសស) ហើយបង់ក្លាដេស បានទទួល ៤,២ពាន់លានដុល្លារ (៧%) ។ ការសិក្សារបស់មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍកសិកម្ម និងធនាគារអភិវឌ្ឍន៍ទ្វីបអាមេរិក (IFAD 2007) រកឃើញថា ពលករចំណាកស្រុកនៅលើពិភពលោកមាន ១៥០លាននាក់ ដែលបានផ្ញើប្រាក់មកផ្ទះ ៣០០ពាន់លានដុល្លារនៅឆ្នាំ២០០៦ គឺលើសពីជំនួយអភិវឌ្ឍន៍ និងវិនិយោគផ្ទាល់ពីបរទេសទៅទៀត ។

## ចំណាកស្រុកចេញពីកម្ពុជាតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ និងប្រាក់ផ្ញើមកផ្ទះ

ពលករចំណាកស្រុកចេញពីកម្ពុជាមានពីរប្រភេទធំៗ គឺ ប្រភេទស្របច្បាប់ និងមិនស្របច្បាប់ ។ យោងតាមស្ថិតិរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ពីឆ្នាំ១៩៩៨ ដល់ចុងឆ្នាំ២០០៧ មានពលករ ១០.៥៣២នាក់ ត្រូវបានបញ្ជូនជាផ្លូវការទៅម៉ាឡេស៊ី ៣៩៨៤នាក់ទៅកូរ៉េខាងត្បូង និង ៦១១៤នាក់ ទៅថៃ (សរុប ២០.៦៣០នាក់) ។ម្យ៉ាងទៀត មានពលករកម្ពុជាប្រហែល ១៨០.០០០នាក់ កំពុងធ្វើការនៅថៃ (IOM 2006) ក្នុងនេះ ១១០.០០០នាក់ បានទទួលលិខិតអនុញ្ញាតឱ្យធ្វើការចេញដោយរដ្ឋាភិបាលថៃនៅឆ្នាំ២០០៤ និងប្រហែល ៥០.០០០នាក់ បានទទួលលិខិតបញ្ជាក់ពីអត្តសញ្ញាណ (CI) ចេញដោយរដ្ឋាភិបាលកម្ពុជាតាមរយៈក្រុមការងារអន្តរក្រសួងដឹកនាំដោយក្រសួងការងារ ។

ពលករទៅម៉ាឡេស៊ីភាគច្រើនជាស្ត្រី ទៅធ្វើជាអ្នកបំរើ រឺអ្នកធ្វើការងារផ្ទះ រីឯពលករទៅកូរ៉េភាគច្រើនជាបុរស ។ ទោះបីប្រទេសថៃធ្លាប់បានទទួលពលករចំណាកស្រុកពីកម្ពុជាតាំងពីឆ្នាំ១៩៩៤ ប៉ុន្តែពលករភាគច្រើនគ្មានឯកសារបញ្ជាក់អ្វីទេ រឺក៏ជាពលករមិនស្របច្បាប់ ។ ការបញ្ជូនពលករចេញជាផ្លូវការ ទើបចាប់ផ្តើមក្នុងឆ្នាំ២០០៦ បន្ទាប់ពីមានអនុស្សរណៈព្រមព្រៀង (MOU) រវាងថៃ និងកម្ពុជា នៅខែឧសភា ឆ្នាំ២០០៣ ។ ពលករចំណាកស្រុកកម្ពុជា ទទួលបានតែការងារណាដែលមានលក្ខណៈក្រខ្វក់ ពិបាក និងគ្រោះថ្នាក់ជាពិសេស ខាងនេសាទ សំណង់ និងកសិកម្ម ។

## បទប្បញ្ញត្តិច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងចំណាកស្រុកពលករ

### *កង្វះក្របខ័ណ្ឌច្បាប់*

ដោយចំណាកស្រុកពលករចេញពីកម្ពុជា ជារឿងមួយថ្មី ហេតុនេះកម្ពុជាត្រូវជួបបញ្ហាប្រឈមក្នុងការបង្កើតគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ សំរាប់គ្រប់គ្រងចំណាកស្រុកពលករចេញ ។ នៅឆ្នាំ១៩៩៥ អនុក្រឹត្យលេខ៥៧ ស្តីពីការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ត្រូវបានអនុម័ត ។ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា[1] នាពេលនោះ ជាអ្នកតាក់តែងសេចក្តីព្រាងអនុក្រឹត្យ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស ។ អនុក្រឹត្យ បានទទួលស្គាល់ពីកង្វះខាតឱកាសការងារក្នុងស្រុក និងបញ្ជាក់ពីគោលដៅកែលំអកំរិតជីវភាពរបស់ប្រជាជនតាមរយៈការរកចំណូល និងទទួលបានជំនាញពីការងារក្រៅស្រុក ។ អនុក្រឹត្យកំណត់ឱ្យក្រសួងទទួលបន្ទុក (ពេលនោះ គឺក្រសួងការងារ) ធ្វើជាអ្នកផ្តល់ធនធានមនុស្ស ហើយក្រុមហ៊ុន រឺទីភ្នាក់ងារជ្រើសរើសពលករ ជាភាគីទទួលយកពលករ ។ ក្រៅពីអនុក្រឹត្យលេខ៥៧ នៅមានប្រកាសលេខ ១០៨ នៅខែឧសភា ឆ្នាំ២០០៦ ស្តីពីការអប់រំអំពីជំងឺអេដស៍ ចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិការងារសំរាប់ពលករកម្ពុជា ធ្វើការនៅក្រៅស្រុក ព្រមទាំងអនុក្រឹត្យលេខ៧០ នៅខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាល ហត្ថពលកម្ម និងបញ្ជូនពលករទៅបរទេស (MTOSB) ។

អ្នកឆ្លើយសំភាសន៍ជាច្រើននាក់លើកឡើងថា កម្ពុជាខ្វះគោលនយោបាយទេសន្តប្រវេសន៍ រឺច្បាប់ជាក់លាក់សំរាប់ចំណាកស្រុក ។ នៅក្នុងគំនិតពួកគេ អនុក្រឹត្យលេខ ៥៧ (ឯកសារច្បាប់ជាធរមានតែមួយគត់ក្រៅពីប្រកាស) មានអាយុកាលយូរពេកហើយ និងគួរតែពិនិត្យកែសំរួលឡើងវិញ ។ ច្បាប់ការងាររបស់កម្ពុជា មិនអាចយកទៅអនុវត្តនៅប្រទេសទទួលយកពលករបានទេ ជាពិសេសទាក់ទិននឹងចំណាកស្រុកពលករ ។

### *កង្វះខាតក្នុងស្ថាប័នរដ្ឋ*

មានទស្សនៈថា គួរមានស្ថាប័នជំនាញដោយឡែកមួយទទួលខុសត្រូវគ្រប់គ្រងចំណាកស្រុកពលករ ។ អាចសមរម្យដែរ បើក្រសួងការងារបង្កើតការិយាល័យ រឺនាយកដ្ឋានមួយដោយឡែក អោយទទួលបន្ទុកជាពិសេសលើចំណាកស្រុកពលករ ។ អ្នកឆ្លើយសំភាសន៍ទាំងអស់ មានមតិឯកភាពគ្នាថា ត្រូវតែបង្កើនចំនួនបុគ្គលិកមានសមត្ថភាព ដើម្បីគ្រប់គ្រងបញ្ហាចំណាកស្រុកពលករដ៏ស្មុគស្មាញនេះ ។ ថវិកាផ្តល់ពីរដ្ឋាភិបាល ក៏អាចត្រូវបង្កើនដែរ ដើម្បីទាក់ទាញមន្ត្រីអ្នកមានសមត្ថភាពសមស្រប ។ ប៉ុន្តែ ក៏គួរមានវិធីសំរាប់អោយការិយាល័យ រឺនាយកដ្ឋាននេះ ទទួលបានថវិកាពីការងារចំណាកស្រុកពលករ ពីព្រោះសកម្មភាពនេះជួយផ្តល់ប្រាក់រាប់រយលានដុល្លារមកក្នុងប្រទេស ។

ដោយសារចំណាកស្រុកពលករពាក់ព័ន្ធនឹងក្រសួងជាច្រើន ហេតុនេះក៏មានការបង្កើតក្រុមការងារអន្តរក្រសួង គ្រប់គ្រងអន្តោប្រវេសន៍ (IMTM) មួយឡើងនាពេលថ្មីៗនេះ ដែលមានសហប្រធានជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងការងារ ។ គំនិតផ្តួចផ្តើមនេះបានផុសឡើងបន្ទាប់ពីមានការតស៊ូមតិបានជោគជ័យរបស់ មូលនិធិអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិដើម្បីស្ត្រី (UNIFEM) ដែលព្យាយាមលើកកំពស់សិទ្ធិរបស់ពលករស្ត្រីចំណាកស្រុក ។ ក្រុមការងារ IMTM មានសមាជិកមកពីក្រសួងសំខាន់ៗ ប៉ុន្តែទើបជួបប្រជុំបាន ២លើកប៉ុណ្ណោះ តាំងពីពេលកកើតឡើង នៅខែតុលា ឆ្នាំ២០០៦ មក ។ ក្រុមការងារនេះនៅថ្មីថ្មោង និងមានការងារជំរុញដោយធនធានបានពី UNIFEM ។ វាជាវេទិកាមួយសំរាប់ឱ្យស្ថាប័នរដ្ឋនានាជួបពិភាក្សាពីបញ្ហាចំណាកស្រុកពលករ និងស្វែងរកការមូលមតិគ្នាមុនពេលទៅជួបចរចារជាមួយប្រទេសជាភាគីទទួលយកពលករ និងមុនពេលតាក់តែងសេចក្តីព្រាងគោលនយោបាយ សំរាប់គ្រប់គ្រងចំណាកស្រុកពលករ ។ គេរំពឹងថា ក្រុមការងារ IMTM នឹងកសាងបាននូវគោលនយោបាយ និងបទប្បញ្ញត្តិដ៏ចាំបាច់នានា ប៉ុន្តែនៅមិនទាន់ដឹងទេថាតើនឹងមានដំណើរការបានសក្តិសិទ្ធិប៉ុណ្ណា ។

### *កង្វះខាតស្ថាប័នឯកជន*

អនុក្រឹត្យលេខ៥៧ បានកំណត់ចំបញ្ហាគ្មានការងារធ្វើ និងបញ្ហាមានការងារមិនគ្រប់គ្រាន់ ព្រមទាំងបង្ហាញពីផលចំណេញ បានមកពីចំណាកស្រុកពលករ ក្នុងការលើកកំពស់កំរិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែមានទិដ្ឋភាពមួយចំនួន បង្ហាញថា គោលបំណងអនុក្រឹត្យ និងគោលនយោបាយមិនស៊ីចង្វាក់គ្នាទេ ដូចជា ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករដាក់

ប្រាក់តំកល់ច្រើន និងចេញសោហ៊ុយចំណាយជាមុន ។

ម្យ៉ាងទៀតគួរមានទីភ្នាក់ងារជ្រើសរើសពលករច្រើនគ្រប់គ្រាន់ ដើម្បីទទួលចាត់ចែងលើពលករចំណាកស្រុកប្រមាណ ២០០.០០០នាក់ (ទាំងស្របច្បាប់ និងខុសច្បាប់) បើសិនចង់ឱ្យពួកគេប្រើប្រាស់មធ្យោបាយស្របច្បាប់ទាំងអស់គ្នា ។ ទាំងស្ថាប័នរដ្ឋ និងឯកជន ត្រូវតែមានច្រើនគ្រប់គ្រាន់ និងរឹងមាំ ។ បច្ចុប្បន្ននេះ កំពុងមានកង្វះខាត ទាំងមន្ត្រីរដ្ឋដែលមានសមត្ថភាពដោះស្រាយបញ្ហាចំណាកស្រុកពលករ និងទីភ្នាក់ងារឯកជនសំរាប់ជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ។

ពិតហើយ កង្វះខាតទីភ្នាក់ងារបញ្ជូនពលករទៅក្រៅស្រុក វាផុសចេញពីលក្ខខណ្ឌដ៏ខ្ពស់ដែលចែងក្នុងអនុក្រឹត្យ ។ ក្រុមហ៊ុនត្រូវដាក់ប្រាក់តំកល់ ១០០.០០០ដុល្លារ នៅឯក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវបង់ចំណាយផ្សេងៗសំរាប់បញ្ជូនពលករ ។ លក្ខខណ្ឌនេះបានដាក់បន្ទុកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរមួយទៅលើក្រុមហ៊ុន ហើយជាមូលហេតុដែល ២៦ ក្រុមហ៊ុន ត្រូវបិទទ្វារក្នុងខែកក្កដា ឆ្នាំ២០០៦ នៅពេលមានការរឹតបណ្តឹងឱ្យដាក់ប្រាក់ដំកល់ ហើយនៅសល់តែ ១២ក្រុមហ៊ុនប៉ុណ្ណោះ ដែលអាចបន្តដំណើរការ ។ នាពេលថ្មីៗ មាន ៤ក្រុមហ៊ុនទៀតបានកកើតឡើង ដូច្នេះសព្វថ្ងៃមាន សរុប ១៦ក្រុមហ៊ុន ដោយមិនរាប់បញ្ចូលនូវទីភ្នាក់ងារ ២ ទៀត ដែលកំពុងព្យាយាមប្រែក្លាយខ្លួន ទៅជាអង្គការមិនមែនរដ្ឋាភិបាល (NGO) ។ យោងតាមប្រទេសដែលមានបទពិសោធន៍យូរអង្វែងក្នុងការនាំចេញពលករទៅបរទេស កម្ពុជានៅមានក្រុមហ៊ុនតិចហួសពេក ។ ជាក់ស្តែង ប្រទេសបង់ក្លាដេស មានប្រមាណ ៨០០ក្រុមហ៊ុន ធ្វើការជ្រើសរើស និង[២] បញ្ជូនពលករទៅបរទេស រីឯហ្វីលីពីន មានច្រើនជាង ១០០០ក្រុមហ៊ុន ។

*ការពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល*

អង្គការមិនមែនរដ្ឋាភិបាល មានសកម្មភាពច្រើនពាក់ព័ន្ធនឹងបញ្ហាចំណាកស្រុក និងការជួញដូរមនុស្ស ។ បណ្តាញ NGO ពាក់ព័ន្ធនឹងចំណាកស្រុក បានបង្កើតឡើងដោយមានការគាំទ្រពី UNIFEM និងការចូលរួមពីអង្គការចំនួន ៣០ ។ អង្គការទាំងនោះ ជួបប្រជុំរៀងរាល់ ២ខែម្តង ដើម្បីអនុវត្តកម្មវិធីចំនួន ៥ ស្តីពី ១) ការបំផុសចំណាប់អារម្មណ៍ និងការតស៊ូមតិ ២) ការស៊ើបអង្កេត ៣) ទិដ្ឋភាពច្បាប់ ៤) ការស្រាវជ្រាវ និងប្រមូលទិន្នន័យ និង ៥) ការកសាងសមត្ថភាព និងទំនាក់ទំនងសាធារណៈ ។ បណ្តាញនេះ ដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារមួយ ដែលមានសមាសភាពមកពីអង្គការសកម្មៗក្នុងបញ្ហាចំណាកស្រុកពលករ និងការជួញដូរមនុស្ស ។[៣]

## បញ្ហាសំខាន់ៗជាគន្លឹះនៅក្នុងការផ្តល់សេវារដ្ឋបាលដល់ចំណាកស្រុកពលករ

*តំលៃដំណើរការបញ្ជូនពលករទៅបរទេស*

ក្រោយពីរដ្ឋាភិបាលកម្ពុជា តែងតាំងឱ្យក្រុមប្រឹក្សាបណ្តុះបណ្តាលហត្ថពលកម្ម និងបញ្ជូនពលករទៅបរទេស (MTOSB) ជាអ្នកចាត់ចែងបណ្តុះបណ្តាល និងបញ្ជូនពលករដោយផ្ទាល់ តម្លៃបញ្ជូនពលករទៅប្រទេសកូរ៉េខាងត្បូង ធ្លាក់ពី ៣០០០ដុល្លារ ក្នុងពលករម្នាក់ មកត្រឹម ៨៩២ដុល្លារប៉ុណ្ណោះ នៅខែមករា ឆ្នាំ២០០៧ ។ នេះជាជោគជ័យដ៏ធំមួយ ដែលផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ពលករ ។ ចំណុចខុសគ្នាខ្លាំង គឺ កំរៃ និងចំណាយបញ្ជូនពលករ ដែលក្រុមហ៊ុនឯកជនទារយកពីពលករ ។ MTOSB មិនបានយកកំរៃទាំងពីរនេះ រឺក៏កំរៃសំរាប់ការអប់រំ/ណែនាំ និងពន្ធអ្វីទេ ហើយចាប់តាំងពីទទួលការងារនេះមក MTOSB បញ្ជូនពលករបានប្រហែល ៥០០នាក់ ។ នេះជាឧទាហរណ៍ជាក់ស្តែងមួយដែល បញ្ជាក់ថា ការកាត់បន្ថយចំណាយក្នុងការបញ្ជូលពលករទៅបរទេស ពិតជាអាចធ្វើបាន ។

នាបច្ចុប្បន្ន តម្លៃបញ្ជូនពលករចំណាកស្រុកទៅធ្វើការនៅថៃ គឺ ៧០០ដុល្លារ ក្នុងនេះ ១០០ដុល្លារ ត្រូវបង់ដោយពលករម្នាក់ៗដែលដាក់ពាក្យសុំចំណាកស្រុក និង ៦០០ដុល្លារ (២០.០០០បាត) ត្រូវបង់ដោយនិយោជក រឺក្រុមហ៊ុនជ្រើសរើសបុគ្គលិក ហើយត្រូវកាត់ ២០០០បាត ក្នុងមួយខែ ចេញពីប្រាក់ខែពលករសំរាប់រយៈពេល ១០ខែ ។ ចំណាយនេះខ្ពស់ណាស់ បើធៀបនឹងប្រាក់ខែរបស់ពលករ ដែលជាមធ្យមទទួលបានប្រហែល ៦០០០បាត ហើយពលករត្រូវធ្វើការថែមម៉ោងដើម្បីអាចសន្សំប្រាក់បានច្រើនផ្ញើមកផ្ទះ ស្របតាមគោលបំណងដែលគេធ្វើចំណាកស្រុក ។ កំរៃមិនផ្លូវការសំរាប់ចំណាកស្រុកខុសច្បាប់ដែលបង់ឱ្យមេខ្យល់ គឺ ១០០ដុល្លារប៉ុណ្ណោះក្នុងពលករម្នាក់ ។ ម្យ៉ាងទៀត ពលករមិនបាច់រង់ចាំយូរទេ បើសិនប្រើមធ្យោបាយខុសច្បាប់ ។ នៅពេលជំរើសនេះអាចប្រើបាននៅឡើយ ពលករភាគច្រើន ប្រាកដជាជ្រើសយកមធ្យោបាយមិនស្របច្បាប់ដែលរហ័ស ដោយបង់ត្រឹម ១០០ដុល្លារ ជាជាងការបង់ប្រាក់ ៧០០ដុល្លារ និងត្រូវរង់ចាំពី ៣-៦ខែ ដើម្បីធ្វើចំណាកស្រុកទៅថៃ ។ ទោះបីអាចត្រូវសមត្ថកិច្ចចាប់ខ្លួន និងបញ្ជូនត្រឡប់មកវិញក្តី ក៏ពលករចំណាកស្រុកភាគច្រើន នៅតែហ៊ានប្រថុយនឹងគ្រោះថ្នាក់ចូលទៅថៃដោយខុសច្បាប់ ។ ពលករដែលធ្លាប់ទៅថៃ តែងចូលទៅប្រទេសនោះម្តងទៀតដោយខ្លួនឯង ហើយចំណាយតែប្រហែល ៥០ដុល្លារប៉ុណ្ណោះ សំរាប់ថ្លៃធ្វើដំណើរ ។

ព្រំដែនដ៏វែងបានធ្វើឱ្យអាជ្ញាធរកម្ពុជា និងថៃ លំបាកនឹងបញ្ឈប់ចំណាកស្រុកខុសច្បាប់ណាស់ ដូច្នេះការងារសំខាន់ គឺត្រូវសំរួលឱ្យចំណាកស្រុកស្របច្បាប់មានតំលៃថោកសមរម្យដែលពលករអាចចំណាយបាន ។ មានការស្នើឡើងថាតម្លៃ ៧០០ដុល្លារ គួរបញ្ចុះមកត្រឹម ៣០០ដុល្លារ ហើយរដ្ឋាភិបាលទាំងពីរ គួរជួយពន្លឿនដំណើរការបញ្ជូនពលករ ។ ក្នុងតំលៃសរុប ៧០០ដុល្លារនេះ ៤៨០ដុល្លារជាចំណាយនៅលើទឹកដីកម្ពុជា ។ លិខិតឆ្លងដែនគួរបញ្ចុះតម្លៃពី ១៥០ដុល្លារ មកត្រឹម ៥០ដុល្លារ ហើយចំណាយផ្សេងៗទៀតគួរបញ្ចុះពី ២២០ដុល្លារ មកត្រឹម ៤០ដុល្លារ ។ វិធីនេះ នឹងកាត់បន្ថយចំណាយនៅកម្ពុជាពី៤៨០ដុល្លារ មកត្រឹម ២០០ដុល្លារ ហើយក្រុមហ៊ុនក៏អាចរក្សាប្រាក់ចំណូលជាមធ្យម ៧០ដុល្លារ នេះបានដដែល ។

រដ្ឋាភិបាលថៃ គួរបញ្ចុះតម្លៃលិខិតអនុញ្ញាតការងារពី ១០៦ដុល្លារ (៣៥០០បាត) មកត្រឹម ៣០ដុល្លារ (១០០០បាត) និងតម្លៃទិដ្ឋាការពី ៥៩ដុល្លារ (២០០០បាត) មកត្រឹម ១៥ដុល្លារ (៥០០បាត) ។ ធ្វើដូច្នេះតម្លៃសរុបនៅខាងថៃ នឹងថយចុះពី ២២០ដុល្លារ មកត្រឹម ១០០ដុល្លារ ។ យោងតាមក្រសួងការងារថៃ តម្លៃទិដ្ឋាការ នឹងកាត់បន្ថយមកត្រឹម ៥០០បាត ប៉ុន្តែមិនទាន់អនុវត្តទេនៅពេលសរសេរអត្ថបទនេះ[៤] ។ ដូច្នេះការងារចំបងដែលរដ្ឋាភិបាលថៃអាចចូលរួមធ្វើ គឺការបញ្ចុះតម្លៃលិខិតអនុញ្ញាតការងារ ។ នៅពេលមានពលករច្រើនៗផ្លាស់ប្តូរទៅប្រើមធ្យោបាយចំណាកស្រុកស្របច្បាប់វិញ រដ្ឋាភិបាលថៃនឹងទទួលបានចំណូលបន្ថែមទៀត ពីការចេញលិខិតអនុញ្ញាតការងារកាន់តែច្រើន ព្រមទាំងផលចំណេញជាច្រើនទៀត ។

*តម្លៃលិខិតឆ្លងដែនកម្ពុជា*

ចាប់ពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ លិខិតឆ្លងដែនមានតម្លៃផ្លូវការ ១២០ដុល្លារ បន្ទាប់ពីបានតម្លើង ២០ដុល្លារទៀតសំរាប់បន្ថែមទិន្នន័យ

អេឡិចត្រូនិក[៥] ។ ប៉ុន្តែគេត្រូវបូកបន្ថែមតំលៃក្រៅផ្លូវការ ១៩ដុល្លារទៀត ដូច្នេះតម្លៃសរុបសំរាប់លិខិតឆ្លងដែនមួយ គឺ ១៣៩ដុល្លារ ។ តម្លៃនេះតំរូវឱ្យសាម៉ីជនរង់ចាំ ២ខែ ទើបទទួលបានលិខិតឆ្លងដែន ហើយបើសិនត្រូវការលិខិតឆ្លងដែនឆាប់ជាងនេះ ប្រជាពលរដ្ឋអាចសុំយកក្នុងរយៈពេល ១សប្តាហ៍ ប៉ុន្តែត្រូវបង់ ២២៤ដុល្លារ ។ រឿងនេះបង្ហាញថា ការចេញលិខិតឆ្លងដែនក្នុងរយៈពេលមួយសប្តាហ៍ អាចធ្វើទៅបាន ហើយការអូសបន្លាយពេល គឺដោយសារបន្ទុកការងារច្រើន រឺបញ្ហាផ្សេងទៀត ។

នៅប្រទេសវៀតណាម តម្លៃលិខិតឆ្លងដែនគឺ ១២ដុល្លារប៉ុណ្ណោះ ហើយរដ្ឋចេញឱ្យក្នុងរយៈពេល ៥ថ្ងៃ រីឯនៅប្រទេសថៃ និងប្រទេសឡាវ គឺ ៣០ដុល្លារ ដោយចេញឱ្យបានក្នុងរយៈពេល ៣ ទៅ ៥ថ្ងៃ ។ ប្រទេសទាំងនេះមានការិយាល័យជាច្រើនសំរាប់ទទួលធ្វើលិខិតឆ្លងដែន រួមទាំងនៅតាមខេត្តផង ។ នៅប្រទេសកម្ពុជាវិញសព្វថ្ងៃ មានតែការិយាល័យតូចមួយនៅភ្នំពេញ ដែលជាឧបសគ្គមួយយ៉ាងច្បាស់រារាំងដល់ដំណើរការធ្វើលិខិតឆ្លងដែនឱ្យបានឆាប់ ។ វាមិនច្បាស់ទេថា តើគេរក្សាដំណើរការធ្វើលិខិតឆ្លងដែនឱ្យយូររហូតដល់ ២ខែ ដូច្នេះដោយចេតនា រឺយ៉ាងណា ដើម្បីឱ្យអ្នកដែលចង់បានឆាប់ត្រូវបង់ប្រាក់ ២២៤ដុល្លារ ហើយតើប្រាក់ ៨០ដុល្លារដែលបូកបន្ថែមនោះត្រូវគេយកទៅណា ។

រាជរដ្ឋាភិបាលកម្ពុជា បានយល់ស្របថា តម្លៃលិខិតឆ្លងដែន វាខ្ពស់ពេកហើយសំរាប់ពលករចំណាកស្រុកដែលភាគច្រើន មកពីគ្រួសារក្រីក្រ ដូច្នេះពលករទាំងនេះ ត្រូវបង់ជាផ្លូវការតែ ៤០ដុល្លារប៉ុណ្ណោះសំរាប់លិខិតឆ្លងដែនមួយ បន្ទាប់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុម័តលើបញ្ជីឈ្មោះ និងបញ្ជូនបញ្ជីទៅក្រសួងមហាផ្ទៃ ។ នៅមុនថ្ងៃទី ៥ ខែមីនា ឆ្នាំ២០០៧ លិខិតឆ្លងដែនមានតំលៃផ្លូវការត្រឹមតែ ២០ដុល្លារ ប៉ុន្តែតម្លៃជាក់ស្តែងអាចលើសពី ៥០ដុល្លារ ហើយប្រើពេល មិនឆាប់ជាង ២ខែទេ ។ ការយឺតយ៉ាវបែបនេះ បានអូសបន្លាយដំណើរការទាំងមូលនៃការបញ្ជូនពលករ ដែលអាចប៉ះពាល់ដល់ទំនុកចិត្តរបស់ពលករផ្ទាល់ និងរបស់និយោជកនៅថៃ ។ ពលករភាគច្រើនមិនអាចរង់ចាំ ៥-៦ខែ ទើបបានចេញទៅធ្វើការនៅបរទេសនោះទេ ។ ហេតុនេះ ពួកគេត្រូវបង្ខំចិត្តសុំធ្វើលិខិតឆ្លងដែនឱ្យបានក្នុងមួយសប្តាហ៍ ដោយសុខចិត្តបង់ប្រាក់ ១៥០-២០០ដុល្លារ ដោយផ្ទាល់ រឺដោយកាត់ប្រាក់ខែសងវិញ ហើយក៏ត្រូវរ៉ាប់រងបន្ទុកចំណាយមួយដ៏ធ្ងន់ ។

ប្រសិនបើពលករទាំង ២០០.០០០នាក់ ត្រូវមានលិខិតឆ្លងដែនទាំងអស់គ្នា ហើយលិខិតឆ្លងដែនមួយគិតថ្លៃត្រឹម ៥០ដុល្លារ ដូច្នេះតំលៃសរុបត្រូវជា ១០លានដុល្លារ ។ ប៉ុន្តែ ការិយាល័យតែមួយយ៉ាងតូចនៅភ្នំពេញ មិនអាចមានកំលាំងគ្រប់គ្រាន់ដើម្បីបំពេញការងារច្រើនបែបនេះឡើយ ។ ដូច្នេះក្រសួងមហាផ្ទៃ គួរបង្កើតការិយាល័យបន្ថែមមួយ ឬពីរទៀតនៅភ្នំពេញ ដើម្បីឱ្យការងារមានប្រសិទ្ធភាពជាងនេះ និងរកចំណូលបានច្រើនថែមទៀត ។ សំខាន់ជាងនេះទៀត ក្រសួងមហាផ្ទៃគួរតែបង្កើតការិយាល័យធ្វើលិខិតឆ្លងដែននៅតាមខេត្តសំខាន់ៗ និងបណ្តុះបណ្តាលឱ្យមន្ត្រីមានសមត្ថភាពអនុវត្តការងារ ។ វិធីនេះមិនត្រឹមតែអាចបំពេញតំរូវការដ៏ច្រើនលើសលប់របស់ប្រជាពលរដ្ឋនោះទេ ប៉ុន្តែថែមទាំងអាចជួយកាត់បន្ថយចំណាយធ្វើដំណើរសំរាប់ប្រជាពលរដ្ឋនៅតាមខេត្តទៀតផង ។ ឧទាហរណ៍ ខេត្តបន្ទាយមានជ័យ បាត់ដំបង និងព្រៃវែង គួរមានការិយាល័យសំរាប់ទទួលពាក្យស្នើសុំ និងធ្វើលិខិតឆ្លងដែន ពីព្រោះនៅទីនោះមានពលករច្រើន ដែលត្រូវការលិខិតឆ្លងដែន ។

*បញ្ហារត់ចោលការងារនៅពេលធ្វើការនៅប្រទេសថៃ*

ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករទទួលរ៉ាប់រងចំណាយបញ្ជូនពលករ គឺជាបញ្ហាមួយ ។ ទីភ្នាក់ងារនឹងខាតបង់ ប្រសិនបើពលករគេចចេញពីការងារជាប់កិច្ចសន្យា ។ យោងតាមទីភ្នាក់ងារជ្រើសរើសពលករ ការរត់ចោលការងារមានអត្រាខ្ពស់គួរសម ជាពិសេសនៅថៃ ។ រឿងនេះអាចយល់បាន ពីព្រោះនៅថៃមានពលករកម្ពុជាតែ ៦១១៤នាក់ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅដោយស្របច្បាប់ ប៉ុន្តែមានពលករកម្ពុជាប្រហែល ១៨០.០០០នាក់ទៀត ដែលកំពុងធ្វើការដោយខុសច្បាប់ ។ ពលករស្របច្បាប់ទំនងជាចង់រត់គេចពីបំណុល ដោយទៅចូលរួមជាមួយពលករដែលគ្មានឯកសារបញ្ជាក់ ។ រឿងនេះ មិនមែនមានតែនៅថៃទេ ។ Dang. (2007) បានរាយការណ៍ថា អត្រារត់ចោលការងាររបស់ពលករវៀតណាមនៅជប៉ុន គឺ ២៧-៣០% នៅកូរ៉េខាងត្បូង ២០-២៥% ហើយនៅតៃវ៉ាន់ ៩-១២% ។

បញ្ហាមួយទៀតគឺ ពលករមួយចំនួនយល់ថា ការងារនៅថៃលំបាកពេក ដូច្នេះពួកគេប្រើគ្រប់មធ្យោបាយដើម្បីត្រឡប់មកផ្ទះវិញ ។ រឿងនេះ ធ្វើឱ្យទីភ្នាក់ងារខាតបង់ប្រាក់ ដែលខ្លួនបានចំណាយមុនដើម្បីបញ្ជូលពលករទៅធ្វើការ ។ វាអាចមកពីទីភ្នាក់ងារមិនបានពន្យល់សព្វគ្រប់ដល់ពលករ រឺក៏អាចមកពីការងារដែលទីភ្នាក់ងារបានសន្យា និងការងារពិតវាមិនដូចគ្នា ។ ទីភ្នាក់ងារ ឬក្រុមហ៊ុនជ្រើសរើសពលករ ក៏មានកំហុសមួយចំណែកដែរក្នុងរឿង ពលកររត់ចោលការងារ ពីព្រោះពួកគេជ្រើសរើសពលករមិនបានត្រឹមត្រូវល្អទេ គឺអ្នកណាក៏យកដែរឱ្យតែបានច្រើន ដើម្បីទទួលបានឆាប់ៗនូវកំរៃសំរាប់ការជ្រើសរើស ។

វាមិនមែនជារឿងងាយស្រួលទេសំរាប់ទីភ្នាក់ងារ ក្នុងការដោះស្រាយបញ្ហាពលកររត់ចោលការងារ ។ ក្នុងករណីខ្លះ ពួកគេស្នើសុំស្ថានទូតថៃអោយជួយរារាំងពលកររត់ចោលការងារ ដោយមិនផ្តល់ទិដ្ឋាការឱ្យទៀត ។ ប៉ុន្តែស្ថានភាពនៅតែច្របូកច្របល់ និងគ្មានដំណោះស្រាយល្អដដែល ។ ខុសគ្នាពីកូរ៉េខាងត្បូង រឺម៉ាឡេស៊ី ដែលមានពលករចំណាកស្រុកភាគច្រើនស្របច្បាប់ និងមិនងាយត្រឡប់មកផ្ទះវិញស្រួលៗដោយគ្មានលិខិតឆ្លងដែននោះ ប្រទេសថៃ គឺជាករណីពិសេស ពីព្រោះទីតាំងភូមិសាស្ត្រ និងការត្រួតពិនិត្យព្រំដែនធូររលុង បានផ្តល់ការងាយស្រួលដល់ពលករក្នុងការរត់ចោលការងារ ហើយបន្តស្នាក់នៅថៃនិងធ្វើការដោយមិនស្របច្បាប់ រឺរត់ត្រឡប់មកផ្ទះវិញ ។

*ការតំរូវឱ្យទីភ្នាក់ងារជ្រើសរើសពលករ ចំណាយជាមុនក្នុងការបញ្ជូនពលករចំណាកស្រុក*

បញ្ហាមួយទៀតគឺ ចំណាយហិរញ្ញវត្ថុនៃការបញ្ជូនពលករទៅក្រៅស្រុក ត្រូវទទួលរ៉ាប់រងដោយក្រុមហ៊ុនជ្រើសរើសពលករ រឺនិយោជកនៅបរទេស ។ វិធីនេះមានន័យថា ក្រុមហ៊ុនត្រូវចំណាយជាមុនយ៉ាងហោចណាស់ ៦០០.០០០ ដុល្លារ ក្នុងការបញ្ជូនពលករ ១០០០នាក់ ទៅក្រៅស្រុកក្នុងមួយលើកៗ ពីព្រោះចំណាយបញ្ជូនពលករម្នាក់ គឺ ៦០០ដុល្លារ ។ នេះជាទឹកប្រាក់យ៉ាងច្រើនដែលត្រូវប្រថុយចំណាយមុន ជាពិសេសសំរាប់ក្រុមហ៊ុនកម្ពុជា ដែលមិនសូវមានទុន ប៉ុន្តែអាចមានសមត្ថភាព ។ ក្រុមហ៊ុនមួយចំនួនបានរាយការណ៍ពីការខាតបង់ច្រើនគួរសម ដែលបណ្តាលមកពីពលកររត់ចោលការងារក្នុងពេលទៅធ្វើការនៅបរទេស និងដែលធ្វើអោយក្រុមហ៊ុនពិបាកនឹងរស់រានមានជីវិត ។ ដោយបានទទួលស្គាល់ពីបន្ទុកទាំងនេះ រដ្ឋាភិបាលមិនជំទាស់ចំពោះការតំរូវឱ្យពលករអ្នកដាក់ពាក្យទៅធ្វើការនៅបរទេស បង់

ដោយខ្លួនឯងនូវថ្លៃធ្វើលិខិតឆ្លងដែន និងចំណាយជាមូលដ្ឋាន ដូចជា ការពិនិត្យសុខភាពជាដើម ។ មានទីភ្នាក់ងារមួយចំនួន បានតំរូវឱ្យពលករ អ្នកដាក់ពាក្យទៅធ្វើការនៅថៃ បង់ប្រាក់ ១០០ដុល្លារ ។

បើសិនជារដ្ឋាភិបាលកម្ពុជា និងថៃ ចង់អោយពលករធ្វើចំណាកស្រុកតាម រយៈក្រុមហ៊ុនជ្រើសរើសពលករ ចំនួនក្រុមហ៊ុនគួរតែមានច្រើនជាងនេះ ។ នាបច្ចុប្បន្ន ចំណាយពាក់កណ្តាល រឺលើសពីនេះទៀត គឺនិយោជកថៃជាអ្នក ទទួលរ៉ាប់រងដោយផ្អែកលើលក្ខខណ្ឌថា ក្រុមហ៊ុនជ្រើសរើសពលករកម្ពុជា ត្រូវផ្តល់ដោយមិនយកកំរៃសេវានូវពលករថ្មី មកជំនួសពលករដែលរត់ ចោលការងារ ។ វិធីនេះបានធ្វើអោយក្រុមហ៊ុនកម្ពុជា ត្រូវប្រឈមនឹង ហានិភ័យយ៉ាងធំ ។

ជារឿងងាយយល់ទេដែល ពលករភាគច្រើនពុំមានប្រាក់ ៦០០ដុល្លារ សំរាប់បង់មុន ។ ប៉ុន្តែរឿងនេះអាចដោះស្រាយបានដោយរកមធ្យោបាយជួយ ពលករដែលចង់ទៅធ្វើការពិតៗ អោយគេទទួលបានប្រាក់កំចីពិសេសមួយ ដែលអាចមាន រឺគ្មានការប្រាក់ ពីធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ កម្មវិធី ឥណទានរបស់ NGO រឺគំរោងសន្សំប្រាក់របស់សហគមន៍ជាដើម ។ ពលករ ដែលត្រូវការរកប្រាក់ឱ្យបានច្រើនពីការងារនៅក្រៅស្រុក អាចត្រូវចំណាយ ប្រាក់ផ្ទាល់ រឺខ្ចីប្រាក់គេសំរាប់បង់អោយទីភ្នាក់ងារជ្រើសរើសពលករ ។ ប្រាក់ កំចី អាចមានការធានាពីអាជ្ញាធរមូលដ្ឋានដែលស្គាល់ពលករនោះច្បាស់ រឺ មានរបៀបរៀបចំផ្សេងៗសំរាប់ជួយធានាការសងប្រាក់វិញ ។

### *ការអនុវត្តអនុស្សារណៈព្រមព្រៀងរវាងកម្ពុជា និងថៃ*

ជាផ្នែកមួយនៃការអនុវត្តអនុស្សារណៈព្រមព្រៀង (MOU) រវាងថៃ និង កម្ពុជា រដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយមាន តំណាងមកពីក្រសួងការងារ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងការបរទេស ដើម្បីផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជា ដែលកំពុងធ្វើការក្នុងប្រទេសថៃ ដោយមិនស្របច្បាប់ ។ ក្រុមការងារថៃ ដែលមានសមត្ថកិច្ចប្រហាក់ប្រហែល (មានសមាជិកមកពីក្រសួងការងារ ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល) ជាអ្នកផ្តល់លិខិតអនុញ្ញាត ឱ្យធ្វើការ ។ ពលករចំណាកស្រុកត្រូវចំណាយ ១៥០០បាត ទៅឱ្យ គណៈកម្មាធិការកម្ពុជា និង ៤០០០បាត ទៅឱ្យគណៈកម្មាធិការថៃសំរាប់ លិខិតអនុញ្ញាតការងារ ដែលតំរូវឱ្យមានការពិនិត្យសុខភាពសំរាប់ដាក់បញ្ចូល ទៅក្នុងប្រព័ន្ធធានាសុខភាព ។ តំលៃសរុបនៃការបញ្ជូនពលករម្នាក់តាម រយៈប្រព័ន្ធ MOU គឺ ៧០០ដុល្លារ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា យល់ឃើញថា ក្នុង៥ឆ្នាំ កន្លងមកនេះ MOU បាននិងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅថៃឱ្យមាន ការទទួលស្គាល់ និងការចាត់ចែងដោយយុត្តិធម៌ ។ យោងតាមការសំភាស ជាមួយមន្ត្រីកម្ពុជា ក្រុមការងារផ្សេងៗដែលធ្វើការអោយក្រសួងការងារ កម្ពុជា និងថៃ បានសហការគ្នាយ៉ាងល្អ ។ កិច្ចប្រជុំរវាងក្រសួងការងារកម្ពុជា និងថៃ នៅសៀមរាប កាលពីចុងខែវិច្ឆិកា ឆ្នាំ២០០៧ បានសំរេចនូវកិច្ច ព្រមព្រៀងមួយថា គណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុកផ្តល់លិខិត បញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាដែលធ្វើការនៅថៃ គឺអាចបន្តការងារ រហូតដល់ចុងខែមិថុនា ឆ្នាំ២០០៨ ។ ម្យ៉ាងទៀតក៏មានសេចក្តីសំរេចបង្កើត គណៈកម្មាធិការមួយនៅកម្ពុជា សំរាប់ទទួលពលករមិនស្របច្បាប់ដែលត្រូវ គេបញ្ជូនមកវិញ នៅពេលលិខិតអនុញ្ញាតឱ្យស្នាក់នៅនិងធ្វើការ នៅថៃបាន ផុតកំណត់ ។ កិច្ចប្រជុំក៏បានសំរេចថា គួរមានអនុស្សារណៈព្រមព្រៀង (MOU) ថ្មីមួយសំរាប់ដោះស្រាយបញ្ហាពលករចូលទៅធ្វើចំការនៅដីថៃនៅ ជិតព្រំដែន ។

ជាទូទៅ គួរមានគ្រឿងលើកទឹកចិត្តផ្តល់អោយនិយោជកថៃ ដែលរួម សហការ និងការដាក់ពិន័យចំពោះនិយោជកអ្នកមិនសហការ ។ អ្នកឆ្លើយ សំភាសន៍មួយចំនួនយល់ថា និយោជកថៃមួយចំនួនចូលចិត្តជួលពលករ ដែល គ្មានឯកសារបញ្ជាក់ ពីព្រោះវាចំណេញជាង ហើយពួកគេអាចធ្វើបាបពលករ តាមចិត្តចង់ ។ មានគេនិយាយថា មួយថ្ងៃ-ពីរថ្ងៃមុនពេលបើកប្រាក់ខែ និយោជកថៃសហការជាមួយប៉ូលីសរករឿងដេញពលករចេញ ហើយយក ប្រាក់ខែនោះ មកចែកគ្នាជាមួយប៉ូលីស ។ បើសិនរឿងនេះជាការពិត គួរមាន គ្រឿងលើកទឹកចិត្តសំរាប់អោយនិយោជកថៃ ណែនាំពលករខុសច្បាប់របស់ ខ្លួនឱ្យទៅចុះបញ្ជី និងការផាកពិន័យ បើសិនមិនបានធ្វើដូច្នេះ ។

### សន្និដ្ឋានអនុសាសន៍

ចំណាយសំរាប់ពលករចំណាកស្រុកទៅថៃដោយស្របច្បាប់ គួរតែកាត់បន្ថយ ដោយចាត់វិធានការណ៍មួយចំនួន ដូចជា ១) ការរៀបចំខាងស្ថាប័ន គួរមាន ការកែលំអ ២) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរមាននាយកដ្ឋាន មួយសំរាប់ទទួលបន្ទុកលើចំណាកស្រុកពលករ និងគួរបន្ថែមបុគ្គលិកមាន សមត្ថភាពឱ្យបានច្រើន សំរាប់ដោះស្រាយបញ្ហាចំណាកស្រុក ៣) គោល នយោបាយចំណាកស្រុក និងក្របខណ្ឌច្បាប់ ដូចជា ច្បាប់អន្តោប្រវេសន៍ គួរមានការពិនិត្យកែសំរួល ៤) ថ្លៃធ្វើលិខិតឆ្លងដែន គួរកាត់បន្ថយមកត្រឹម ៥០ដុល្លារ ក្នុងរយៈពេល ១០ថ្ងៃ និង ៥) ក្រសួងមហាផ្ទៃគួរបង្កើត ការិយាល័យបន្ថែមទៀតសំរាប់ធ្វើលិខិតឆ្លងដែន ដោយមានទីតាំងនៅភ្នំពេញ និងនៅតាមខេត្តសំខាន់ៗ ដូចជា បាត់ដំបង បន្ទាយមានជ័យ និងព្រៃវែង ។

ក្រុមហ៊ុន និងការិយាល័យជ្រើសរើសពលករ គួរមានច្រើនថែមទៀតនៅ តាមខេត្តដែលមានពលករធ្វើចំណាកស្រុកទៅថៃច្រើន ។ អនុក្រឹត្យលេខ ៥៧ គួរមានការពិនិត្យកែតំរូវឡើងវិញ ដើម្បីឱ្យសមស្របនឹងការវិវត្ត នាពេលថ្មីៗ ។ ប្រាក់តម្កល់សំរាប់បើកទីភ្នាក់ងារជ្រើសរើសពលករ (១០០.០០០ដុល្លារ នាបច្ចុប្បន្ន) គួរតែកាត់បន្ថយ ដើម្បីបង្កើនចំនួនទីភ្នាក់ងារ ប្រភេទនេះ ។ ទីភ្នាក់ងារនានា គួរជ្រើសរើសពលករដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាង មានពលករច្រើនរត់ចោលការងារ ។ រឿងនេះក៏អាចធ្វើ ឡើងដោយមានការសហការពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) ផងដែរ ។ ទន្ទឹមនឹងនេះ គួរអនុញ្ញាតឱ្យទីភ្នាក់ងារយកកំរៃសេវាអំពីពលករ ដែលចង់ទៅធ្វើការនៅថៃ រឺប្រទេស ផ្សេងទៀត ពីព្រោះវិធីនេះ អាចជួយកាត់ បន្ថយចំនួនពលកររត់ចោលការងារ ។

ប្រទេសថៃជាអ្នកទទួលប្រយោជន៍ពីពលករចំណាកស្រុក ហេតុនេះ រដ្ឋាភិបាលថៃគួរជួយឱ្យពលករទាំងនោះមានលក្ខណៈផ្លូវការ ។ រដ្ឋាភិបាលថៃ គួរចូលរួមចំណែកកាត់បន្ថយចំណាយរត់ការផ្សេងៗ (សំរាប់លិខិតអនុញ្ញាត ការងារ និងទិដ្ឋាការ) និងគួរចាត់វិធានការបញ្ឈប់ការជួលពលករមិនស្រប ច្បាប់ ។ គ្រឿងលើកទឹកចិត្ត គួរផ្តល់ឱ្យនិយោជក ដែលជួលពលករស្របច្បាប់ រីឯអ្នកជួលពលករមិនស្របច្បាប់គួរតែទទួលការពិន័យ ។ ចំពោះពលករ កំពុងធ្វើការនៅថៃ គួរមានវិធីជួយពួកគេឱ្យមានសិទ្ធិធ្វើការនៅទីនោះដោយ ស្របច្បាប់ ដោយមិនចាំបាច់ឱ្យពួកគេមកធ្វើលិខិតឆ្លងដែន និងសុំទិដ្ឋាការ នៅភ្នំពេញទេ ។ គួរមានការកាត់បន្ថយរាល់ចំណាយដែលពាក់ព័ន្ធនឹងការ បញ្ជូនពលករស្របច្បាប់ ។

*តទៅទំព័រទី ១៧*